

# តើមានសុវត្ថិភាពដែរឬទេ ក្នុងការចាក់វ៉ាក់សាំងការពារកូវីដ-១៩ ប្រសិនបើខ្ញុំកំពុងមានផ្ទៃពោះ ?



មិនមានហានិភ័យដែលត្រូវបានគេស្គាល់ទាក់ទងនឹងការចាក់វ៉ាក់សាំងនេះនៅឡើយទេ ក្នុងអំឡុងពេលមានផ្ទៃពោះ



អ្នកម្តាយគ្រប់រូបគួរតែទទួលការចាក់វ៉ាក់សាំងនៅពេល៖

- ការប្រឈមនិងហានិភ័យនៃការឆ្លងខ្ពស់ (ដូចជាអ្នកផ្តល់សេវាជួរមុខ)




វ៉ាក់សាំងដែលបានចាក់មិនបង្ករឱ្យមានការឆ្លងមេរោគជំងឺកូវីដ-១៩ចំពោះម្តាយ ឬកូនក្នុងផ្ទៃដែលមិនទាន់កើតនោះទេ



- ឬក៏ពួកគេមានជំងឺប្រចាំកាយ ដូចជាជំងឺលើសឈាម ឬហឺត




អ្នកម្តាយដែលបានចាក់វ៉ាក់សាំងទាំងអស់ត្រូវតែបន្តពាក់ម៉ាស់ឱ្យបានត្រឹមត្រូវ រក្សាគំលាតសុវត្ថិភាព និងលាងដៃឱ្យបានទៀងទាត់ដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩






សម្រាប់ព័ត៌មានបន្ថែម សូមប្រឹក្សាជាមួយឆ្មបរបស់អ្នក ឬស្វែងរកព័ត៌មានបន្ថែមអំពីគោលនយោបាយវ៉ាក់សាំងសម្រាប់ស្ត្រីមានផ្ទៃពោះ នៅក្នុងប្រទេសរបស់អ្នក តាមរយៈ៖ ទូរស័ព្ទទៅកាន់ ១១៥ ដោយឥតគិតថ្លៃ

Australian Aid
គាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី



# តើខ្ញុំគួរចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ទេ ប្រសិនបើខ្ញុំកំពុងបំបៅកូនដោយទឹកដោះ ?



មិនមានហានិភ័យដែលត្រូវបានគេស្គាល់ទាក់ទងនឹងការចាក់វ៉ាក់សាំងនេះនៅឡើយ  សម្រាប់ម្តាយដែលបំបៅកូនដោយទឹកដោះ ឬទារកដែលកំពុងបៅទឹកដោះម្តាយ



អ្នកម្តាយដែលបំបៅកូនដោយទឹកដោះ និងជាអ្នកដែលធ្វើការជួរមុខ ឬដែលងាយរងគ្រោះគួរតែត្រូវបានផ្តល់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩




អ្នកម្តាយដែលបានចាក់វ៉ាក់សាំងទាំងអស់ត្រូវតែបន្តពាក់ម៉ាស់ឱ្យបានត្រឹមត្រូវ រក្សាគំលាតសុវត្ថិភាព និងលាងដៃឱ្យបានទៀងទាត់ដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩






សម្រាប់ព័ត៌មានបន្ថែម សូមប្រឹក្សាជាមួយធ្មបរបស់អ្នក ឬស្វែងរកព័ត៌មានបន្ថែមអំពីគោលនយោបាយវ៉ាក់សាំងសម្រាប់ស្ត្រីមានផ្ទៃពោះ នៅក្នុងប្រទេសរបស់អ្នក តាមរយៈ៖  ទូរស័ព្ទទៅកាន់  ១១៥  ដោយឥតគិតថ្លៃ

Australian Aid

គាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី